សេចក្តីប្រកាសព័ត៌មាន

# អេមរ៉ុាយស៍ ទទួលបានការវិនិយោគពី EMIA ដើម្បីលើកកម្ពស់កម្ពុជាក្នុងនាមជាអ្នកផលិត និងនាំចេញអង្ករគុណភាពខ្ពស់




**ភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣** - Emerging Markets Investment Advisers (EMIA) ដែលមានមូលដ្ឋាននៅប្រទេសសិង្ហបុរី បានប្រកាសពីការវិនិយោគដំបូងរបស់ខ្លួននៅក្នុងក្រុមហ៊ុនអេមរ៉ុាយស៍ (Amru Rice) ដែលជាក្រុមហ៊ុនផលិត និងនាំចេញអង្ករសរីរាង្គដែលមានការទទួលស្គាល់ធំជាងគេរបស់កម្ពុជា តាមរយៈមូលនិធិថ្មីរបស់ខ្លួនគឺ ASEAN Frontier Markets Fund (AFMF)។

ពីការចាប់ផ្តើមក្នុងនាមជាក្រុមហ៊ុនពាណិជ្ជកម្មអង្ករតូចមួយដែលបានបើកដំណើរការក្នុងឆ្នាំ ២០១១ រហូតដល់ការធ្វើសមាហរណកម្មជាអ្នកផលិត និងអ្នកនាំចេញអង្ករនាពេលបច្ចុប្បន្ន អេមរ៉ុាយស៍ ផ្តោតចម្បងលើសុខុមាលភាពរបស់កសិករដែលជាស្នូលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន។ ជាមួយនឹងចក្ខុវិស័យក្នុងការការគាំទ្រដល់កសិករខ្នាតតូចឱ្យរួចផុតពីភាពក្រីក្រ អេមរ៉ុាយស៍ ធ្វើការជាមួយកសិករក្នុងស្រុកជាង ២ម៉ឺននាក់ ក្នុងនោះស្ត្រីមានរហូតដល់ទៅជាង ៥០% តាមរយៈគំរូកសិកម្មតាមកិច្ចសន្យា ដោយផ្តល់ជូននូវប្រព័ន្ធលើកទឹកចិត្តបប្រកបដោយដោយសមភាព និងកម្មវិធីអភិវឌ្ឍសមត្ថភាព ក្នុងចំណោមកម្មវិធីដទៃទៀតដើម្បីបង្កើតឱ្យមាននិរន្តរភាពនិងបរិយាបន្ននៃខ្សែសង្វាក់ផ្គត់ផ្គង់។

ជាមួយនឹងការបោះជំហានចូលទៅក្នុងភាពប្រកួតប្រជែងខ្ពស់ដើម្បីសហការជាមួយនឹងកសិករ និងចាប់យកនូវការអនុវត្តផលិតកម្មកសិកម្មដ៏ល្អបំផុត ផលិតផលរបស់ អេមរ៉ុាយស៍ ពិតជាបាននិងកំពុងទទួលបានជំហររឹងមាំនៅក្នុងការប្រកួតប្រជែងជាសកល។ ផលិតផលអង្កររបស់ អេមរ៉ុាយស៍ ទទួលបានបានគាំទ្រនិងស្វាគមន៍ក្នុងរូបភាពវិជ្ជមានពីសំណាក់អតិថិជននៅទូទាំងសហភាពអឺរ៉ុប អាមេរិកខាងជើង និងបណ្តាប្រទេសអាស៊ី ដែលឆ្លុះបញ្ចាំងពីតួនាទីកាន់តែលេចធ្លោរបស់ អេមរ៉ុាយស៍ ក្នុងការពង្រឹងវត្តមានអង្ករកម្ពុជានៅលើឆាកអន្តរជាតិ។

ក្នុងនាមជាតួអង្គដ៏សំខាន់ និងមានឥទ្ធិពលក្នុងវិស័យស្រូវអង្ករបស់ប្រទេសកម្ពុជា អេមរ៉ុាយស៍ ប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍមិនត្រឹមតែទៅលើភាពជោគជ័យនៃអាជីវកម្មប៉ុណ្ណោះទេ ថែមទាំងទៅលើនិរន្តរភាព និងក្រមសីលធម៌នៃអាជីវកម្ម ដោយការអនុវត្តនូវស្តង់ដារបរិស្ថានខ្ពស់បំផុត ការអនុវត្តអភិបាលកិច្ចនិងសង្គម (ESG)។ ការអនុវត្តអភិបាលកិច្ចនិងសង្គម (ESG) ត្រូវបានជំរុញដោយការប្តេជ្ញាចិត្តដើម្បីធ្វើឱ្យមានភាពខុសគ្នា។ ការឈានមុខរបស់ការអនុវត្តអភិបាលកិច្ចនិងសង្គម(ESG) នឹងនៅតែជាស្នូលនៅក្នុងដំណាក់កាលរីកចម្រើនបន្ទាប់ របស់ក្រុមហ៊ុន អេមរ៉ុាយស៍។ នាពេលអនាគតដ៏ខ្លី អេមរ៉ុាយស៍ មានគោលបំណងបង្កើតឥណទានកាបូនដំបូងគេ តាមរយៈការកាត់បន្ថយការបំភាយឧស្ម័នតាមរយៈការអនុវត្តកសិកម្មបែបថ្មី។

អេមរ៉ុាយស៍ ទទួលបានការគាំទ្រពីមូលនិធិហូឡង់សម្រាប់អាកាសធាតុ និងការអភិវឌ្ឍ ដែលជាកម្មវិធីសម្របខ្លួន និងកាត់បន្ថយអាកាសធាតុបែបពហុប្រទេស ដើម្បីនាំមកនូវការអនុវត្តកសិកម្មបែបបង្កើតឡើងវិញ សម្រាប់ការកែលម្អគុណភាពដី និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលសមាជិកនៃធនាគារពិភពលោកក៏ធ្លាប់បានផ្តល់ការគាំទ្រដល់ក្រុមហ៊ុន អេមរ៉ុាយស៍ ក្នុងការអនុម័តស្តង់ដារវេទិកាស្រូវអង្ករប្រកបដោយនិរន្តរភាព (SRP) ដែលបំពាក់បំប៉នដល់ក្រុមហ៊ុន និងកសិករដែលបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឱ្យបំពេញតាមតម្រូវការលក្ខខណ្ឌរបស់អ្នកទិញអន្តរជាតិ។ ការគាំទ្ររបស់អង្គការអន្តរជាតិទាំងនេះ គឺជាការទទួលស្គាល់ដ៏រឹងមាំនូវសមិទ្ធផល និងការប្តេជ្ញាចិត្តរបស់ អេមរ៉ុាយស៍ ចំពោះការអនុវត្តប្រកបដោយនិរន្តរភាព។

**លោកឧកញ៉ា សុង សារ៉ន ស្ថាបនិក និងជាអគ្គនាយកក្រុមហ៊ុន អេមរ៉ុាយស៍** បានមានប្រសាសន៍ថា៖ "អេមរ៉ុាយស៍ មានកិត្តិយសក្នុងការស្វាគមន៍ EMIA ក្នុងការចូលរួមកិច្ចការងារជាមួយគ្នា។ វត្តមានដ៏រឹងមាំនិងយូរអង្វែងរបស់ EMIA នៅក្នុងតំបន់ និងប្រកបដោយបណ្តាញទំនាក់ទំនងយ៉ាងទូលំទូលាយ ស្តែងពីតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់ពួកយើង ខណៈដែលក្រុមហ៊ុនរបស់យើងបានឆ្លងកាត់នូវដំណាក់កាលបន្ទាប់ នៃដំណើរបំពេញបេសកកម្មរបស់យើង។ យើងពិតជាក្តីសោមនស្សចំពោះការប្តេជ្ញាចិត្តរបស់ EMIA លើដំណើរអភិវឌ្ឍន៍របស់ក្រុមហ៊ុនដែល EMIA វិនិយោគទាំងផ្នែកពាណិជ្ជកម្ម និងការអនុវត្តអភិបាលកិច្ចនិងសង្គម (ESG) ។ ការវិនិយោគរបស់ AFMF នឹងរំពឹងទុកជាកាតាលីករសម្រាប់ អេមរ៉ុាយស៍ ក្នុងការពន្លឿនកំណើនអាជីវកម្មរបស់ខ្លួន និងអនុវត្តរបៀបវារៈការអនុវត្តអភិបាលកិច្ចនិងសង្គម (ESG) និងអាកាសធាតុ ដើម្បីផលប្រយោជន៍សំខាន់ៗដល់ភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់"។

**លោក ម៉ៅ សាវីន ប្រធាន EMIA Cambodia** និងជាអ្នកដឹកនាំនូវកិច្ចព្រមព្រៀងសម្រាប់ អេមរ៉ុាយស៍ មានប្រសាសន៍ថា៖ "ទន្ទឹមនឹងការសាទរចំពោះការរីកចម្រើនប្រកបដោយភាពធន់របស់ អេមរ៉ុាយស៍ និងគំរូអាជីវកម្មប្រកបដោយនិរន្តរភាពក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ EMIA មានសេចក្តីសោមនស្សរីករាយក្នុងការចូលរួមជាមួយ អេមរ៉ុាយស៍ ក្នុងដំណើរសម្រេចឱ្យបាននូវចក្ខុវិស័យដ៏គួរឱ្យរំភើបក្នុងការក្លាយជាអ្នកផលិត និងនាំចេញអង្ករសរីរាង្គឈានមុខគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ជាមួយនឹងបេសកកម្មគាំទ្រដល់ក្រុមហ៊ុនដែលមានទស្សនវិជ្ជារួមដូចគ្នាជាមួយ AFMF លើការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ EMIA ជឿជាក់ថាភាពជាដៃគូនេះនឹងគាំទ្រដល់

ក្រុមហ៊ុន អេមរ៉ាយស៍ ក្នុងការរីកចម្រើន និងពង្រីកអាជីវកម្មបន្ថែមទៀត ដើម្បីបង្កើនចំណែករបស់កម្ពុជានៅក្នុងទីផ្សារអង្ករពិភពលោក ជាពិសេសទីផ្សារអង្ករសរីរាង្គដែលមានតម្លៃខ្ពស់។ ខ្ញុំទន្ទឹងរង់ចាំការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយ អេមរ៉ាយស៍ ដើម្បីបង្កើតផលវិជ្ជមានកាន់តែច្រើនលើវិស័យស្រូវអង្ករ អ្នកពាក់ព័ន្ធសំខាន់ៗ និងសហគមន៍ដែល អេមរ៉ាយស៍ សហការជាមួយ"។

**លោក Joshua Morris នាយកប្រតិបត្តិនៃ EMIA** ក៏បានមានប្រសាសន៍ផងដែរថា៖ "យើងពិតជារំភើបណាស់ដែល អេមរ៉ាយស៍ ក្លាយជាក្រុមហ៊ុនដែលទទួលបានការវិនិយោគដំបូងសម្រាប់មូលនិធិថ្មីរបស់ AFMF យើង។ ជាមួយនឹងទម្រង់អាជីវកម្មដែលរីកចម្រើនយ៉ាងឆាប់រហ័សរបស់ អេមរ៉ាយស៍ និងតួនាទីដ៏ពិសេសក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ក៏ដូចជាវិធីសាស្ត្រដែលមិនធ្លាប់មានពីមុនមកក្នុងការពង្រឹងសមត្ថភាពសង្គម និងការការពារបរិស្ថានពិតជាបានស្តែងឱ្យឃើញពីលក្ខណៈរបស់ក្រុមហ៊ុនដែលយើងចង់គាំទ្រ។ ភាពជាដៃគូនេះក៏បញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងក្នុងការកសាងអាជីវកម្មប្រកបដោយភាពច្នៃប្រឌិត តម្លាភាព និងនិរន្តរភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ យើងទន្ទឹងរង់ចាំការពង្រីកបណ្តាញក្រុមហ៊ុនតម្លៃបន្ថែមរបស់យើង ដែលជំរុញដល់ការរីកចម្រើនផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គមរបស់ទីផ្សារក្នុងស្រុក»។

## អំពី អេមរ៉ាយស៍

អេមរ៉ាយស៍ បង្កើតឡើងក្នុងឆ្នាំ២០១១ ចាប់ផ្តើមពីក្រុមហ៊ុនពាណិជ្ជកម្មអង្ករដែលមានចក្ខុវិស័យក្លាយជាអាជីវកម្មកសិឧស្សាហកម្មឈានមុខគេក្នុងវិស័យកសិកម្មប្រកបដោយសីលធម៌ និងការទទួលខុសត្រូវ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនបានអនុវត្តសមាហរណកម្មបន្តិចម្តងៗជាមួយនឹងការបង្កើតកន្លែងកែច្នៃផ្ទាល់ខ្លួននៅក្នុងរាជធានីភ្នំពេញ កំពង់ធំ និងខេត្តបាត់ដំបង តាមរយៈការគ្រួសត្រាយផ្លូវទៅក្នុងកិច្ចសន្យាកសិកម្មជាមួយសហគមន៍កសិកម្ម ដើម្បីអភិវឌ្ឍខ្សែសង្វាក់ផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព។

## អំពី EMIA & AFMF

EMIA ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩ ជាអ្នកគ្រប់គ្រងមូលនិធិប្រមូលទុនវិនិយោគដែលបានចុះបញ្ជីនៅប្រទេសសិង្ហបុរី មានបេសកកម្មប្តេជ្ញាក្នុងការកសាងអាជីវកម្មប្រកបដោយភាពច្នៃប្រឌិត តម្លាភាព និងនិរន្តរភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ មូលនិធិរបស់ EMIA ត្រូវបានវិនិយោគនៅក្នុងក្រុមហ៊ុនចំនួន២០នៅទូទាំងវិស័យជាច្រើននៅក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលជំរុញដល់យុទ្ធសាស្ត្រវិនិយោគកាន់តែទូលំទូលាយ។ ចំនេះដឹង និងបណ្តាញរបស់ EMIA នៅក្នុងទីផ្សារទូទាំងពិភពលោកបានផ្តល់នូវសមត្ថភាពផ្សេងៗគ្នាដល់ EMIA ក្នុងការចូលរួមជាមួយក្រុមហ៊ុនឈានមុខគេ និងធានាបាននូវភាពជាដៃគូដ៏ជោគជ័យជាមួយនឹងសមត្ថភាពបង្កើតតម្លៃរយៈពេលវែងសម្រាប់ក្រុមហ៊ុនវិនិយោគរបស់ពួកគេ។

AFMF គឺជាមូលធនទីបីរបស់ EMIA។ ដោយទទួលបានទុនវិនិយោគរហូតដល់ទៅជិត៥០លានដុល្លារ នៅក្នុងខែធ្នូ ឆ្នាំ២០២២ និងដាក់ទិសដៅទៅដល់ជិត៩០លានដុល្លារ មូលនិធិនេះបន្តនូវយុទ្ធសាស្ត្រវិនិយោគដឹកនាំដោយស្ថាបនិក។ មូលនិធិនេះនឹងផ្តល់ការគាំទ្រដល់ក្រុមហ៊ុនដែលមានសក្តានុពល និងផ្តល់ផលជាវិជ្ជមាន និងរួមចំណែកដល់ការអភិវឌ្ឍទីផ្សារនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ មូលនិធិនេះត្រូវបានគាំទ្រដោយអង្គការអន្តរជាតិ រួមមាន IFC, DEG, FMO, Norfund និង Swedfund៕

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់: http://www.emergingmarkets.asia/investments/

**Emerging Markets Investment Advisers**:

Mr. Mao Savin, mao.savin@emergingmarkets.asia

Mr. Joshua Morris, joshua.morris@emergingmarkets.asia